រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

042KH01A-01

គោលជំនឿសំខាន់ៗ



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

៤២

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™



ព្រះជាម្ចាស់ និង ការបើកសំដែងរបស់ព្រះអង្គ

ព្រះឯកត្រីអង្គ

មានព្រះពិតតែមួយគត់ ។ នៅក្នុងព្រះគម្ពីរមានសេចក្តីចែងដែលនាំអោយយើងទទួលស្គាល់ថា ព្រះជាម្ចាស់មានអង្គបី ។ «ព្រះ-ឯកត្រីអង្គ » មានន័យថា «អង្គបីរួមជាព្រះតែមួយ » គឺព្រះបិតា ព្រះបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ ។ អង្គទាំងបីមានទ្ធានុភាព និង ភាពល្អឥតខ្ចោះស្មើៗគ្នា ។

ព្រះជាម្ចាស់មានតែមួយព្រះអង្គគត់

(ម៉ាកុស ១២:២៩-៣០) ។

កំណត់ចំណាំ :

© Project WorldReach © SEAN

កំណត់ចំណាំ :

ព្រះជាម្ចាស់ ជា :

- ព្រះបិតា (១ កូរិនថូស ៨:៦) ។
- ព្រះបុត្រា (យ៉ូហាន ១:១, ១:១៤, ១:៤៩) ។
- ព្រះវិញ្ញាណដ៏វិសុទ្ធ (យ៉ូហាន ១៥:២៦) ។

អង្គទាំងបីដែលរួមគ្នាមិនដែលបែកគ្នានេះ តែងតែធ្វើការរួមជាមួយគ្នា (១ កូរិនថូស ១២:៣-៦, ២ កូរិនថូស ១៣:១៣-១៤, ១ ពេត្រុស ១:២) ។

អង្គទាំងបីរបស់ព្រះឯកត្រីអង្គ មិនគង់នៅដាច់ដោយឡែកពីគ្នាទេ ។ ពួក «សួរបន្ទាល់ព្រះយេហូវ៉ា» បដិសេធមិនទទួលថាព្រះយេស៊ូជាព្រះជាម្ចាស់ស្មើនឹងព្រះបិតាឡើយ ។

ព្រះយេស៊ូគ្រីស្តជាព្រះជាម្ចាស់ គឺព្រះយេស៊ូរួមជាមួយព្រះបិតា និង ព្រះវិញ្ញាណដ៏វិសុទ្ធជាព្រះតែមួយ :

- ម៉ាថាយ ១:២៣, ២៨:១៧-១៩ ។
- ម៉ាកុស ១៤:៦១-៦២ ។
- យ៉ូហាន ១:១-៣, ១៧:៥ ។

© Project WorldReach © SEAN

- ភីលីព ២:៥-១១ ។
- កូឡូស ១:១៥-១៩, ២:៩-១០ ។
- ហេប្រឺ ១:៨ ។

ព្រះបិតា ព្រះបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ មានចរិតលក្ខណៈដូចគ្នា :

- ភាពបរិសុទ្ធ (អេសាយ ៦:៣) ។
- ឯកភាព (ជាព្រះជាម្ចាស់តែមួយ) (ទុតិយកថា ៦:៤) ។
- ប្រភពនៃជីវិត (យ៉ូហាន ៥:២៦) ។
- ការមិនចេះប្រែប្រួល (យ៉ាកុប ១:១៧) ។
- ភាពអស់កល្ប (១ ធីម៉ូថេ ៦:១៦) ។
- បុគ្គលិកលក្ខណៈ គឺមានគំនិត អារម្មណ៍ និង ព្រះហឫទ័យ (ទុតិយកថា ៣:១៤) ។
- សេចក្តីស្រឡាញ់ (១ យ៉ូហាន ៤:៨) ។
- ភាពគ្រប់លក្ខណ៍ឥតខ្ចោះ (ម៉ាថាយ ៥:៤៨) ។

កិច្ចការដែលត្រូវអនុវត្ត

- ធ្វើយ៉ាងណាអោយសមាជិកក្រុមជំនុំអ្នកយល់អំពីគោលជំនឿដែលមានពន្យល់នៅក្នុងកូនសៀវភៅនេះ ។

កំណត់ចំណាំ :

© Project WorldReach © SEAN

ការប្រឡង (សំនួរសង្ខេបមេរៀន)

១- តើពាក្យ «ព្រះឯកត្រីអង្គ» មានន័យយ៉ាងដូចម្តេច ? ។

_____

_____

_____

២- តើមនុស្សបានសង្គ្រោះ ដោយរបៀបណា ? ។

_____

_____

_____

_____

៣- ហេតុអ្វីបានជាជំនឿដែលគ្មានការប្រព្រឹត្តអំពើល្អ ជាជំនឿស្លាប់ ? ។

_____

_____

_____

_____

- សេចក្តីពិត (១ យ៉ូហាន ៥:២០) ។
- បុទ្ធានុភាព (កំណើតពិភពលោក ១៧:១) ។
- មានវត្តមាននៅគ្រប់ទីកន្លែង (១ ពង្សាវតារក្សត្រ ៨:២៧) ។
- ការជ្រាបដឹងគ្រប់បែបយ៉ាង (ហេប្រឺ ៤:១៣) ។
- យុត្តិធម៌ (ទុតិយកថា ៣២:៤) ។

ចរិតលក្ខណៈទាំងនេះ ជាចរិតលក្ខណៈពិសេសៗបំផុតរបស់ព្រះអង្គ ។ ព្រះជាម្ចាស់បានបង្កើតសភាវៈអោយមានចរិតលក្ខណៈទាំងនេះខ្លះ ។ ឧទាហរណ៍ មនុស្សមានសេចក្តីស្រឡាញ់ ព្រោះព្រះជាម្ចាស់បានបង្កើតយើងឱ្យមានលក្ខណៈដូចព្រះអង្គ ហើយព្រះអង្គជាប្រភពតែមួយនៃសេចក្តីស្រឡាញ់គ្រប់លក្ខណ៍ ។ ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ ។ ព្រះបិតា ព្រះបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធបង្កើតអ្វីៗគ្រប់យ៉ាងពីទទេ ។ ព្រះជាម្ចាស់ជាចៅក្រមដ៏ខ្ពង់ខ្ពស់បំផុត ។ ទ្រង់ជាព្រះដ៏វិសុទ្ធ ហើយមានគ្រប់ព្រះចេស្តា ។ ព្រះអង្គសក្តិសមអោយយើងស្រឡាញ់គ្រប់យ៉ាង អោយយើងថ្វាយបង្គំ និង ប្រតិបត្តិតាមផងដែរ ។

ព្រះបិតា ព្រះបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ បង្កើតអ្វីៗគ្រប់យ៉ាងពីទទេ ។

ព្រះជាម្ចាស់ជាចៅក្រមដ៏ខ្ពង់ខ្ពស់បំផុត ។ ទ្រង់ជាព្រះដ៏វិសុទ្ធ ហើយមានគ្រប់ព្រះចេស្តា ។ ព្រះអង្គសក្តិសមឱ្យយើងស្រឡាញ់គ្រប់យ៉ាង អោយយើងថ្វាយបង្គំ និង ប្រតិបត្តិតាមផងដែរ ។

គោលដៅរបស់មនុស្ស គឺលើកតម្កើងសិរីរុងរឿងរបស់ព្រះជា-ម្ចាស់ និង មានអំណរជាមួយព្រះអង្គជារៀងរហូត ។ យើងមិនអាចយករូបភាព ឬ មនុស្ស ឬ វត្ថុសំរាប់ថ្វាយបង្គំណាផ្សេង មកជំនួសព្រះជាម្ចាស់ទេ ។ យើងអធិស្ឋានទៅកាន់ព្រះបិតា ដោយនូវព្រះនាមព្រះបុត្រា តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ (ម៉ាថាយ ៦:៩, យ៉ូហាន ១៦:២៤, អេភេសូ ៦:១៨) ។





ស្ថានបរមសុខជាកន្លែង ដែលពោរពេញ
ដោយព្រះហឫទ័យប្រណីសន្តោស និង
មេត្តាករុណារបស់ព្រះជាម្ចាស់ សំរាប់
ពួកអ្នកដែលបានថ្វាយជីវិតទៅព្រះគ្រីស្ត ។

© Project WorldReach © SEAN

ការរស់ឡើងវិញរបស់ពួកអ្នកជឿដែលបានស្លាប់ទៅហើយ មានអាថិកំបាំងខ្លះ ។ ប៉ុន្តែ វគ្គគម្ពីរទាំងនេះ បង្ហាញពីព្រះហឫទ័យព្រះជាម្ចាស់ និង បុទ្ធានុភាពដែលព្រះអង្គប្រទានចំពោះអស់អ្នកដែលជឿ ហើយបានស្លាប់ទៅហើយ និង អស់អ្នកដែលជឿ ប៉ុន្តែនៅរស់នៅឡើយ ។

ការជំនុំជំរះចុងក្រោយបង្អស់

នៅពេលជំនុំជំរះ ពួកអ្នកដែលគ្មានឈ្មោះក្នុងបញ្ជីជីវិត នឹងទទួលទោសអស់កល្ប ។ ពួកអ្នកទាំងនោះ គឺពួកអ្នកដែលមិនប្រតិបត្តិតាមព្រះគ្រីស្តជាព្រះអម្ចាស់ និង ព្រះសង្គ្រោះ ។ លោកយ៉ូហានបាននិមិត្តឃើញអំពីការជំនុំជំរះ និង អំពីបឹងភ្លើង នៅក្នុង វិវរណៈ ២០:១១-១៥ ។

ព្រះជាម្ចាស់នឹងជំនុំជំរះយើង ស្របទៅតាមអំពើ ដែលយើងបានប្រព្រឹត្ត (វិវរណៈ ២០:១២) ។ ការវិនិច្ឆ័យរបស់ព្រះជាម្ចាស់ប្រកបដោយយុត្តិធម៌ និង គ្រប់លក្ខណ៍ ។ ព្រះជាម្ចាស់នឹងដាក់ទោសពួកអ្នកដែលបដិសេធព្រះគ្រីស្ត អោយសមនឹងទោស ដែលពួកគេត្រូវទទួល ។

ព្រះបិតា

កិច្ចការខ្លះរបស់ព្រះបិតា គឺ :

- ចាត់ព្រះបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធអោយមកធ្វើកិច្ចការរបស់ព្រះអង្គ ។
  - យ៉ូហាន ១៤:១៦, ១៤:២៦ ។
  - យ៉ូហាន ១៧:៨, ១៧:១៨ ។
- គ្រោងទុកគ្រប់គំរោងការ និង ធ្វើឱ្យបានសំរេចគ្រប់កិច្ចការដែលស្របទៅតាមផែនការរបស់ព្រះអង្គ ។
  - អេសាយ ១៤:២៦-២៧ ។
  - អេសាយ ៤៦:៩-១៣ ។
  - ម៉ាថាយ ២៦:៤២ ។
  - រ៉ូម ៨:២៨-៣០ ។
  - អេភេសូ ១:១១ ។
  - អេភេសូ ៣:១០-១១ ។

ព្រះបុត្រា ជាព្រះសង្គ្រោះតែមួយគត់

ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះ ហេតុនេះហើយបានជាព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គ អោយមកយករូបអង្គជាមនុស្ស ។ ព្រះបុត្រាធ្វើអោយក្រិត្យវិន័យរបស់ព្រះជាម្ចាស់បានសំរេច ដោយសារការស្លាប់បង្គាប់ដ៏គ្រប់លក្ខណ៍ ។ ព្រះ-បុត្រាបានបូជាជីវិត ដើម្បីលោះមនុស្សលោកឱ្យរួចពីទោសយ៉ាងធ្ងន់ធ្ងរ ដែលមនុស្សគ្រប់គ្នាក្នុងពិភពលោកត្រូវទទួល ។ ព្រះបុត្រារងការឈឺចាប់លើឈើឆ្កាង ដើម្បីមនុស្សទាំងអស់ ដែលពោរពេញដោយអំពើបាប (យ៉ូហាន ៣:១៦) ។

ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ហើយយាងឡើងទៅស្ថានបរមសុខ (លូកា ២៤:៣៤,៥១) ។ ព្រះអង្គគង់នៅខាងស្តាំព្រះបិតា និង អធិស្ឋានទូលអង្វរអោយពួកអ្នកជឿទាំងអស់ (រ៉ូម ៨:៣៤) ។

ព្រះយេស៊ូជាស្ពានមេត្រីតែមួយរវាងព្រះជាម្ចាស់ និង មនុស្សលោក (១ ធីម៉ូថេ ២:៥) ។

ការប្រោសអោយរស់ឡើងវិញ

ព្រះគ្រីស្តមានព្រះជន្មរស់ឡើងវិញ ហើយយាងទៅស្ថានបរមសុខ ។ ហេតុការណ៍នេះ ជាការអស្ចារ្យធំបំផុតក្នុងសម្ពន្ធមេត្រីថ្មី ។ ព្រះ-គ្រីស្តប្រោសប្រទានអោយយើងកើតជាថ្មី និង ចូលរួមមានជីវិតអស់កល្បជាមួយព្រះអង្គ តាមរយៈការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ (១ កូរិនថូស ១៥:១៧-២៣, អេភេសូ ២:៤-៧, ១ ពេត្រុស ១:៣) ។

មុនពេលជំនុំជំរះ មនុស្សស្លាប់ទាំងអស់នឹងរស់ឡើងវិញ ។ ព្រះ-គ្រីស្ត នឹងប្រោសអ្នកដែលស្គាល់ព្រះអង្គអោយរស់ឡើងវិញ ដើម្បីមានជីវិតអស់កល្ប ។ អស់អ្នកណាដែលមិនជឿលើព្រះជាម្ចាស់នឹងត្រូវប្រោសឱ្យរស់ឡើងវិញដែរ តែដើម្បីវិនាសបាត់បង់ ដោយ«ការស្លាប់លើកទីពីរ» ក្នុងស្ថាននរក (យ៉ូហាន ៥:២៥-២៩, វិវរណៈ ២០:១១-១៥) ។

អ្នកជឿដែលបានស្លាប់ផុតទៅហើយ«សំរាន្តលក់»ព្រះជាម្ចាស់នឹងនាំគេអោយទៅនៅជាមួយព្រះអង្គ គឺគេនឹងរស់ឡើងវិញ (១ ថេស្សាឡូនិក ៤:១៣-១៧, យ៉ូហាន ៥:២៥, លូកា ២៣:៤៣, ២ កូរិនថូស ៤:១៤-១៨, ៥:១-៨, អេភេសូ ២:៦, ភីលីព ១:២១-២៣) ។

© Project WorldReach © SEAN

នៅក្នុង ម៉ាថាយ ២៤:២៣-២៧ ព្រះយេស៊ូទូន្មានប្រាប់យើងថា÷ *«ប្រសិនបើមានគេប្រាប់អ្នករាល់គ្នាថា÷ "ព្រះគ្រីស្តគង់នៅទីនេះ ឬនៅទីនោះ" កុំជឿគេឡើយ ដ្បិតនឹងមានមនុស្សក្លែងខ្លួនធ្វើជាព្រះគ្រីស្ត ព្រមទាំងមានព្យាការីក្លែងក្លាយ នាំគ្នាសំដែងទីសំគាល់ធំអស្ចារ្យ និង ទិព្វាជិហារិយ៍ផ្សេងៗ ដើម្បីបញ្ឆោតមនុស្សរហូតដល់ទៅនាំពួកអ្នក ដែលព្រះជាម្ចាស់បានជ្រើសរើស អោយវង្វេងថែមទៀតផង ប្រសិនបើគេអាចធ្វើបាន ។ ខ្ញុំនិយាយប្រាប់ឱ្យអ្នករាល់គ្នាដឹងជាមុនឱ្យហើយ ។ បើមានគេប្រាប់អ្នករាល់គ្នាថា "ព្រះអង្គនៅវាលរហោស្ថានឯណោះ !" កុំចេញទៅតាមគេឡើយ ឬមួយបើគេថា "ព្រះអង្គនៅក្នុងបន្ទប់ឯណោះ !" ក៏កុំជឿពាក្យគេដែរ ដ្បិតបុត្រមនុស្សនឹងយាងមក ប្រៀបបីដូចជាផ្លេកបន្ទោរ ភ្លឺឆ្វាចឆ្លុតកាត់ពីទិសខាងកើតទៅទិសខាងលិច »* ។

ព្រះយេស៊ូគ្រីស្តជាព្រះ ហើយព្រះអង្គក៏ជាមនុស្សដែរ (១ កូរិនថូស ១៥:២១-២២, រ៉ូម ៥:១៥) ។ ព្រះយេស៊ូគ្រីស្តមិនមែនមានភាពជាព្រះពាក់កណ្តាល ជាមនុស្សពាក់កណ្តាលនោះទេ គឺព្រះអង្គជាព្រះមួយរយភាគរយ និង ជាមនុស្សមួយរយភាគរយ ។

ព្រះយេស៊ូមាននិស្ស័យពេញលេញទាំងពីរ គឺនិស្ស័យជាព្រះ និងនិស្ស័យជាមនុស្ស ។ និស្ស័យទាំងពីររួមគ្នាក្នុងបុគ្គលតែមួយ ។ ហេតុនេះហើយបានជាព្រះអង្គបង្រួបបង្រួមយើងជាមួយព្រះជាម្ចាស់ (យ៉ូហាន ១៤:៩, ១៧:២១-២៣) ។ ទោះជាយើងរស់ក្តី ឬ ស្លាប់ក្តី ក៏យើងមានសង្ឃឹមជាក់ច្បាស់ថា យើងជាបុត្រធីតារបស់ព្រះយេស៊ូដែរ (យ៉ូហាន ១០:២៨) ។

ព្រះវិញ្ញាណដ៏វិសុទ្ធ

ព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះអង្គ អោយគង់នៅជាមួយពួកអ្នកដែលជឿលើព្រះគ្រីស្ត (កិច្ចការ ២:៣៨, អេភេសូ ១:១៣) ។ ព្រះវិញ្ញាណដ៏វិសុទ្ធប្រទានឱ្យយើងកើតជាថ្មី (យ៉ូហាន ៣:៣-៨) ប្រោសអោយយើងក្លាយជាសមាជិករបស់ក្រុមជំនុំ/ព្រះសហគមន៍ ដែលជាព្រះកាយរបស់ព្រះគ្រីស្ត (១ កូរិនថូស ១២:១៣) និង ដៅសញ្ញាសំគាល់ថា យើងជារបស់ព្រះជាម្ចាស់ (អេភេសូ ១:១៣-១៤) ។ ម៉្យាងទៀត ព្រះវិញ្ញាណដ៏វិសុទ្ធ

បំពេញយើង ព្រមទាំងប្រទានឱ្យយើងនូវបុប្ផានុភាព និង អំណោយទានសំរាប់បំរើព្រះជាម្ចាស់ ។ ព្រះគ្រីស្តធ្វើកិច្ចការក្នុងយើងតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ ដែលធ្វើអោយយើងមានលក្ខណៈដូចព្រះគ្រីស្តគ្រប់យ៉ាង ។

វគ្គព្រះគម្ពីរសំខាន់ៗអំពីព្រះវិញ្ញាណដ៏វិសុទ្ធ :

- កិច្ចការរបស់ព្រះអង្គ (យ៉ូហាន ជំពូក ១៤-១៦) ។
- ការផ្តល់សក្ខីភាពឱ្យព្រលឹងវិញ្ញាណរបស់យើង (រ៉ូម ៨) ។
- ការយាងមករបស់ព្រះអង្គនៅថ្ងៃទីហាសិប (កិច្ចការ ២) ។
- ផលផ្លែនៃព្រះវិញ្ញាណដ៏វិសុទ្ធ (កាឡាទី ៥:២២-២៣) ។
- អំណោយទានរបស់ព្រះអង្គ (រ៉ូម ១២:៤-៨, ១ កូរិនថូស ជំពូក ១២ និង ១៤) ។

ព្រះគម្ពីរ

ព្រះគម្ពីរជាអំណាចខ្ពស់បំផុត ដែលយើងត្រូវយកមកធ្វើជាគ្រឹះរបស់គោលជំនឿ សេចក្តីបង្រៀន និង របៀបរបបក្នុងក្រុមជំនុំ ។ អ្នកជឿត្រូវបកស្រាយព្រះគម្ពីរ ដោយពឹងផ្អែកលើការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីកសាងខ្លួនអោយរីកចំរើន និង ដើម្បីអាចបង្រៀនអ្នកឯទៀត (២ ធីម៉ូថេ ២:២) ។

- ព្រះអង្គនឹងប្រោសមនុស្សស្លាប់អោយរស់ឡើងវិញ ហើយបំផ្លាស់បំប្រែពួកអ្នកជឿដែលនៅរស់អោយមានរូបកាយថ្មីដែរ (១ កូរិនថូស ១៥:៥១-៥២, ១ ថេស្សាឡូនិក ៤:១៦-១៧) ។
- ព្រះអង្គនឹងជំនុំជំរះពិភពលោក (២ ថេស្សាឡូនិក ២:១-៨, ២ ពេត្រុស ៣:៧-១០) ។

មនុស្សខ្លះខិតខំគណនារកពេល ដែលព្រះអម្ចាស់នឹងយាងមកវិញ ។ ឧទាហរណ៍ និកាយខុសឆ្គង « ស្មរបន្ទាល់ព្រះយេហូវ៉ា » (Jehovah's Witnesses) បានគណនាឃើញថា ព្រះអម្ចាស់យេស៊ូនឹងត្រឡប់មកវិញនៅឆ្នាំ ១៩១៤ ។ តែមិនឃើញមានអ្វីសោះ ។ ប៉ុន្តែ ពួកគេនៅតែប្រកាសយ៉ាងរឹងមាំថា ព្រះអង្គបានយាងមក ដោយមិនឱ្យអ្នកណាឃើញទេ ! ពួក « អាត់វ៉ែនទីស្ត » (Adventists) ក៏បានគណនាថា ព្រះអម្ចាស់នឹងយាងមកនៅឆ្នាំ ១៨៤៣ ដែរ ។

ថ្ងៃអនាគត

ការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ត

ព្រះអម្ចាស់នៃយើងនឹងយាងមកជាមួយពួកទេវទូតរបស់ព្រះអង្គ ដើម្បីប្រោសមនុស្សស្លាប់អោយរស់ឡើងវិញ ហើយលើកយកក្រុមជំនុំរបស់ព្រះអង្គទៅជាមួយព្រះអង្គ និង ជំនុំជំរះលោកីយ៍ ។

- យើងនឹងមើលឃើញការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់យេស៊ូគ្រីស្ត (ម៉ាថាយ ២៤:៣០, កិច្ចការ ១:១១, វិវរណៈ ១:៧) ។
- ព្រះអម្ចាស់នឹងយាងមក ប្រៀបដូចជាចោរចូលលួច ពេលយប់ដូច្នេះដែរ គឺនៅពេលដែលយើងមិនបានគិតថា ព្រះអង្គនឹងយាងមក (ម៉ាថាយ ២៤:៤២-៤៤, ២ ពេត្រុស ៣:១០) ។
- ព្រះអម្ចាស់នឹងយាងមក ដើម្បីប្រទានសិរីរុងរឿងដល់ពួកអ្នកដែលព្រះអង្គបានប្រោសលោះ និង ដើម្បីបង្កើតអ្វីៗជាថ្មី (រ៉ូម ៨:១១, ៨:១៩-២៣, ២ ពេត្រុស ៣:១៣, វិវរណៈ ២១:១) ។

ព្រះគម្ពីរជាព្រះបន្ទូល ដែលព្រះជាម្ចាស់បានមានបន្ទូល ដោយផ្ទាល់ ។ ព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះអង្គបណ្តាលចិត្តអ្នក ដែលសរសេរព្រះគម្ពីរ អោយសរសេរសេចក្តីពិត ។ ព្រះគម្ពីរជាសេចក្តីសាររបស់ព្រះជាម្ចាស់ផ្ញើមកកាន់មនុស្ស ។ ព្រះជាម្ចាស់បានបើកសំដែងប្រាប់យើង ក្នុងព្រះគម្ពីរ ពេញលេញសព្វគ្រប់ហើយ ។ ហេតុនេះយើងមិនអាចបន្ថែម ឬ បន្ថយអ្វីមួយនៅក្នុងព្រះគម្ពីរទេ (វិវរណៈ ២២:១៨-១៩) ។ សៀវភៅផ្សេងៗទៀត អាចជួយកសាងយើងអោយរីកចំរើនឡើងខាងព្រលឹងវិញ្ញាណ តែមិនមែនព្រះជាម្ចាស់បណ្តាលអោយសរសេរទេ ហើយក៏គ្មានអំណាចដូចព្រះគម្ពីរដែរ ។

«គ្រប់អត្ថបទគម្ពីរ សុទ្ធតែព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកបំភ្លឺអោយតែង និង មានប្រយោជន៍សំរាប់បង្រៀន រកខុសត្រូវ កែតម្រង់ និង អប់រំអោយរស់តាមសេចក្តីសុចរិត ក្នុងគោលបំណងអោយអ្នកបំរើរបស់ព្រះជាម្ចាស់មានសមត្ថភាព និង ប្រុងប្រៀបខ្លួនជាស្រេច ដើម្បីប្រព្រឹត្តអំពើល្អគ្រប់ជំពូក » ។

(២ ធីម៉ូថេ ៣:១៦-១៧)

ត្រូវធ្វើយ៉ាងណាអោយអាចអាន និង រិះគិតវគ្គមួយរបស់ព្រះគម្ពីរ អោយបានរាល់ថ្ងៃ ដើម្បីអាចស្គាល់ព្រះជាម្ចាស់ និង ប្រតិបត្តិតាមព្រះហឫទ័យរបស់ព្រះអង្គ ។

សេចក្តីសង្ខេប - ព្រះជាម្ចាស់បើកសំដែងអោយមនុស្សស្គាល់ព្រះអង្គ តាមរបៀបបីយ៉ាង

- តាមរយៈព្រះបុត្រារបស់ព្រះអង្គ (ហេប្រឺ ១:១-៣) ។
- តាមរយៈព្រះបន្ទូលរបស់ព្រះអង្គ (តាមរយៈជំនឿ) (ទំនុកតម្កើង ១៩:៧-១០, រ៉ូម ១០) ។
- តាមរយៈធម្មជាតិ ដែលរួមមានទាំងនិស្ស័យរបស់មនុស្ស យើងផ្ទាល់ផងដែរ (ទំនុកតម្កើង ១៩:១-៧, រ៉ូម ១:១៩-២០, ២:១៤-១៥) ។

នៅពេលដែលយើងរស់ឡើងវិញនៅពេលខាងមុខ យើងនឹងឃើញព្រះគ្រីស្តទល់មុខគ្នានឹងយើង ហើយព្រះជាម្ចាស់នឹងបើកសំដែងអោយយើងស្គាល់ព្រះអង្គយ៉ាងច្បាស់ (១ កូរិនថូស ១៣:១២, ១ យ៉ូហាន ៣:២) ។

សព្វថ្ងៃនេះ ពួកទេវទូតដែលធ្លាក់ចុះទាំងនោះ ជាវិញ្ញាណអាក្រក់ដែលមានឥទ្ធិពលអាក្រក់មកលើពិភពលោក (អេភេសូ ២:១-៣) ។ មារសាតាំងល្បួង និង ចោទប្រកាន់យើង (ម៉ាថាយ ៤:៣, វិវរណៈ ១២:១០) ។ ជួនកាល កងទ័ពខ្មោចរបស់មារសាតាំងជាច្រើនចូលទៅក្នុងមនុស្ស (លូកា ៨:២៦-៣៣) ។ ពួកវាក៏សាបព្រោះសេចក្តីបង្រៀនក្លែងក្លាយដែរ ។ ពួកវាបន្លំខ្លួនធ្វើដូចជាទេវទូតនៃពន្លឺ ដើម្បីបោកបញ្ឆោតមនុស្ស (ម៉ាថាយ ៧:១៥, ២ កូរិនថូស ១១:១៣-១៥, ១ ធីម៉ូថេ ៤:១) ។

យើងជាគ្រីស្តជនត្រូវពង្រីកព្រះរាជ្យរបស់ព្រះជាម្ចាស់ ដោយមិនខ្លាចមារសាតាំង និង ពួកខ្មោចបិសាចរបស់វាទេ ។ ពេលដែលយើងផ្សាយដំណឹងល្អ អធិស្ឋាន តមអាហារ និង រស់នៅដោយសុចរិត និង ដោយអំណរក្នុងជំនឿ នោះយើងចូលធ្វើការប្រយុទ្ធខាងព្រលឹងវិញ្ញាណហើយ ។ នៅពេលជំនុំជំរះចុងក្រោយ មារសាតាំងជាទេវទូតដែលធ្លាក់ចុះពីស្ថានបរមសុខមកនោះ និង អ្នកដែលបដិសេធសេចក្តីសង្គ្រោះក្នុងព្រះគ្រីស្ត នឹងទទួលទោសនៅក្នុងបឹងភ្លើង (ម៉ាថាយ ២៥:៤១, យូដាស ខ ៦, វិវរណៈ ២០:១០-១៥) ។

ដើម្បីអាចដឹងពត៌មានច្រើនជាងនេះ សូមអានក្អូនសៀវភៅ « ការយកឈ្នះលើភាពងងឹត » ។

សភាវៈខាងព្រលឹងវិញ្ញាណ

ទេវទូត

ព្រះជាម្ចាស់បង្កើតទេវទូត ។ ទេវទូតជាសភាវៈខាងព្រលឹងវិញ្ញាណ ដែលបំរើព្រះអង្គ (ហេប្រឺ ១:៧, វិវរណៈ ៥:១១) ។ ទេវទូត បំរើ និង ថែរក្សាអ្នកដែលព្រះជាម្ចាស់បានប្រោសលោះ (ហេប្រឺ ១:១៤) ។ ទេវទូតមានអំណាច តែមិនដូចព្រះជាម្ចាស់ទេ ហើយ ក៏មិនដឹងអ្វីៗគ្រប់យ៉ាងដែរ ។ យើងមិនត្រូវថ្វាយបង្គំទេវទូតទេ (១ ពេត្រុស ១:១២, វិវរណៈ ១៩:៩-១០) ។ ទេវទូតនឹងអម ហែរហមព្រះអម្ចាស់ ពេលព្រះអង្គយាងមកជាលើកទីពីរ (ម៉ាថាយ ២៥:៣១) ។

អារក្ស

មារសាតាំងឈ្មោះលូស៊ីហ្វើរ ធ្លាប់ជាទេវទូតដែលមានប្រាជ្ញា និង មានរូបសម្បត្តិល្អ (អេសេគីអែល ២៨:១២-១៥) ។ ប៉ុន្តែ មារ សាតាំងបះបោរប្រឆាំងនឹងព្រះជាម្ចាស់ ហើយនាំទេវទូតផ្សេងទៀត អោយធ្លាក់ចុះមកជាមួយខ្លួន ។

ការប្រោសលោះ

ការប្រោសលោះជាការរំដោះយើងឱ្យរួចពីទោសនៃអំណាចរបស់ អំពើបាប និង ពីសេចក្តីស្លាប់ តាមរយៈការសុគត និង ការរស់ ឡើងវិញរបស់ព្រះអម្ចាស់យេស៊ូគ្រីស្ត ។

មនុស្ស - ការធ្លាក់ចុះ និង ភាពមានទោស

ព្រះជាម្ចាស់បង្កើតមនុស្សដំបូង ក្នុងភាពល្អឥតខ្ចោះ តែមនុស្ស ដំបូងមិនស្តាប់តាមព្រះអាទិកររបស់ខ្លួន ទើបធ្លាក់ចុះក្នុងអំពើបាប (កំណើតពិភពលោក ជំពូក ២ និង ៣) ។ យើងដែលជាពូជ ពង្សរបស់លោកអាដាម សុទ្ធតែជាមនុស្សបាបដែលរឹងចចេស (យ៉ាកុប ៥:២០) ។ យើងប្រព្រឹត្តអំពើបាបដោយចេតនា ។ ដោយសារមាននិស្ស័យធ្លាក់ចុះក្នុងអំពើបាប ទើបមនុស្សគ្រប់ៗរូប ត្រូវជាប់ទោស ហើយនឹងត្រូវទទួលការជំនុំជំរះទោស ដោយ យុត្តិធម៌ពីព្រះជាម្ចាស់ (រ៉ូម ៥:១២-១៩) ។

យើងអាចដឹងបានថា យើងមានអំពើបាប ដោយសារក្រិត្យវិន័យ របស់ព្រះជាម្ចាស់ ។ តែដោយសារយើងមានសភាពធ្លាក់ចុះក្នុង អំពើបាប ទើបយើងមិនអាចប្រតិបត្តិតាមក្រិត្យវិន័យរបស់ព្រះអង្គ (រ៉ូម ៣:២០, ៧:៧) ។

អំពើបាបចូលមកក្នុងពិភពលោកតាមរយៈលោកអាដាម ហើយ
ឆ្លងរាលដាលដល់យើងទាំងអស់គ្នា (រ៉ូម ៥:១២) ។ ប៉ុន្តែ យើង
ពុំអាចដោះសាយកត្រូវខ្លួនឯងទេ ព្រោះយើងត្រូវទទួលខុសត្រូវ
ចំពោះការប្រព្រឹត្តរបស់យើង (រ៉ូម ៣:២៣) ។ យើងមិនអាច
ដោះសាខ្លួន ដោយនិយាយថា÷ «ខ្ញុំមិនខុសទេ គឺបាបដែលទាញ
ខ្ញុំវិញទេតើ »បាននោះទេ ។ ព្រះជាម្ចាស់ស្អប់អំពើបាប ។ បើសិន
ជាយើងយល់ដឹងអំពីកំហុសដ៏ធ្ងន់ធ្ងរខ្លាំងរបស់យើង ហើយនិងពី
ការដែលយើងត្រូវទទួលទោសនោះ យើងប្រាកដជាស្វែងរកការ
សង្គ្រោះជាមិនខាន ។

ក្រុមជំនុំ/ព្រះសហគមន៍ត្រូវសហការជាមួយរដ្ឋាភិបាលគ្រប់យ៉ាង
តាមដែលអាចធ្វើទៅបាន តែបើសិនជាក្រុមជំនុំចូលរួមជាមួយរដ្ឋ-
អំណាច ក្រុមជំនុំនឹងក្លាយជាឧបករណ៍របស់រដ្ឋាភិបាលលោកីយ៍
ដែលសំរាប់តែរយៈពេលខ្លីមួយប៉ុណ្ណោះ ។

ក្រុមជំនុំនៃព្រះគ្រីស្តជាព្រះសហគមន៍**សកល ខាងព្រលឹងវិញ្ញាណ**
និង **ស្ថិតស្ថេរជារៀងរហូត** ។ ក្រុមជំនុំ និង រដ្ឋជាស្ថាប័នពីរផ្សេង
ដាច់ដោយឡែកពីគ្នា ។ នៅទីកន្លែងដែលអាចធ្វើបាន យើងត្រូវ
ធ្វើអោយសមាជិករបស់រដ្ឋាភិបាល ស្គាល់ដឹងអំពីក្រិត្យវិន័យរបស់
ព្រះជាម្ចាស់ ដើម្បីអោយពួកគេបង្កើត និង កាន់តាមច្បាប់ ស្រប
តាមព្រះបន្ទូលព្រះជាម្ចាស់ ។

© Project WorldReach © SEAN

ក្រុមជំនុំ និង រដ្ឋអំណាច

ព្រះជាម្ចាស់តាំងអោយមានប្រទេស ដោយមានដែនដី និងរដ្ឋាភិ-បាល ដែលគ្រប់គ្រងប្រជាជាតិរបស់ខ្លួន គឺដើម្បីអោយសង្គមមាន សណ្តាប់ធ្នាប់ ។ យើងត្រូវអធិស្ឋានអោយរដ្ឋអំណាច និងស្តាប់ បង្គាប់រដ្ឋអំណាច (រ៉ូម ១៣:១-៧, ១ ធីម៉ូថេ ២:១-៣) ។ យើងចូលរួមចំណែកក្នុងសង្គមជាពលរដ្ឋល្អ ហើយគោរពតាម ច្បាប់ បើសិនជាច្បាប់នោះ មិនប្រឆាំងនឹងក្រិត្យវិន័យរបស់ព្រះ-ជាម្ចាស់ទេ ។ ព្រះជាម្ចាស់ដឹកនាំមនសិការរបស់យើង (កិច្ចការ ៥:២៦-២៩) ។

យើងត្រូវបែងចែកក្រុមជំនុំ/ព្រះសហគមន៍ពីរដ្ឋ ។ ចំពោះក្រុម-ជំនុំ និង រដ្ឋ មិនត្រូវឱ្យមួយណាខិតខំដឹកនាំមួយណាទេ ។ ព្រះ-គ្រីស្តមានបន្ទូលថា៖ *«អ្វីៗដែលជារបស់ព្រះចៅអធិរាជ ចូរថ្វាយ ទៅព្រះចៅអធិរាជវិញទៅ ហើយអ្វីៗដែលជារបស់ព្រះជាម្ចាស់ ចូរថ្វាយទៅព្រះជាម្ចាស់វិញដែរ »* (ម៉ាថាយ ២២:២១) ។ នៅក្នុង យ៉ូហាន ១៨:៣៦ ព្រះអង្គ ក៏ពន្យល់ដែរថា៖ *«រាជ្យរបស់ខ្ញុំ មិនមែននៅក្នុងលោកនេះទេ »* ។



ហេតុអ្វីបានជាយើងមិនអាចបន្ទោសលោកអាដាម ដោយសារតែយើងប្រព្រឹត្តអំពើបាប ? ។

ក្រោយដែលមនុស្សស្លាប់ទៅ នឹងមានការវិនិច្ឆ័យទោស (ហេប្រឺ ៩:២៧) ។ យើងរស់នៅក្នុងលោកីយ៍នេះតែម្តងទេ ។ ដូចនេះ «ការចាប់ជាតិ» ជាពាក្យភូតភររបស់មារសាតាំងទេ ហើយការដែលមនុស្សថា មានផ្លូវសំរាប់អោយមនុស្សកែប្រែវាសនារបស់ខ្លួនក្រោយពេលគេស្លាប់ទៅនោះ ក៏ជាការភូតភររបស់មារសាតាំងដែរ ។

ថ្ងៃរបស់ព្រះអម្ចាស់

នៅក្នុងព្រះគម្ពីរសម្ពន្ធមេត្រីថ្មី ថ្ងៃទីមួយនៃសប្តាហ៍ហៅថា÷ «ថ្ងៃរបស់ព្រះអម្ចាស់» (វិវរណៈ ១:១០) ពីព្រោះព្រះអម្ចាស់យេស៊ូគ្រីស្តមានព្រះជន្មរស់ឡើងវិញ នៅថ្ងៃទីមួយនៃសប្តាហ៍ (យ៉ូហានជំពូក ១៩, ២០:១) ។ ពួកអ្នកជឿជួបជុំគ្នានៅថ្ងៃទីមួយនោះដើម្បីកាច់នំប៉័ង សិក្សាព្រះបន្ទូល ថ្វាយបង្គំ និង ដាក់ប្រាក់ជង្វាយជាមួយគ្នា (១ កូរិនថូស ១៦:១-២) ។

លែងមានការប្រកាន់ថ្ងៃឈប់សំរាក (ថ្ងៃសប្ប័ទ) ដូចកាលនៅក្នុងសម្ពន្ធមេត្រីចាស់ទៀតហើយ (រ៉ូម ១៤:៥-៦, កូឡូស ២:១៦) ។ ថ្ងៃទីប្រាំពីរចង្អុលបង្ហាញពី «សម្ពន្ធមេត្រីចាស់» (ទុតិយកថា ២០:១១) ។ ថ្ងៃទីមួយចង្អុលបង្ហាញអំពី «សម្ពន្ធមេត្រីថ្មីក្នុងអង្គព្រះយេស៊ូគ្រីស្ត» (កូឡូស ១:១៨) ។ ការប្រកាន់យកថ្ងៃអាទិត្យ ដើម្បីប្រជុំគ្នា មិនមែនជាសេចក្តីបង្គាប់របស់ព្រះ-គ្រីស្តទេ តែពួកសាវ័កប្រកាន់យកថ្ងៃនេះ សំរាប់ជួបជុំគ្នា ដើម្បីថ្វាយបង្គំ ។

តើយើងជាគ្រីស្តជនជារបស់សម្ពន្ធមេត្រីចាស់ ឬ សម្ពន្ធមេត្រីថ្មី ? ។

ក្រុមជំនុំដំបូង តែងធ្វើពិធីកាច់នំបុ័ងរាល់ថ្ងៃ (កិច្ចការ ២:៤២-៤៦) ។ ក្រោយមក ក្រុមជំនុំនៅត្រូអាសជួបជុំគ្នា នៅថ្ងៃអាទិត្យ ធ្វើពិធី «កាច់នំបុ័ង» (កិច្ចការ ២០:៧) ។ ក្រុមជំនុំដែលធ្វេសប្រហែសមិនធ្វើពិធីកាច់នំបុ័ង ជាក្រុមជំនុំមិនស្តាប់បង្គាប់របស់ព្រះគ្រីស្ត និង មិនលើកតម្កើងសិរីរុងរឿងរបស់ព្រះអម្ចាស់ ។

«អ្នកណាពិសាសាច់ និង លោហិតរបស់ខ្ញុំ អ្នកនោះស្ថិតនៅក្នុងខ្ញុំ ហើយខ្ញុំក៏ស្ថិតនៅក្នុងអ្នកនោះដែរ...» (យ៉ូហាន ៦:៥៦) ។



សេចក្តីខាងក្រោមនេះ ជាការប្រៀបធៀបរវាងពូជពង្សលោកអាដាម និង ពួកអ្នកដែលរួមជាមួយព្រះយេស៊ូគ្រីស្ត :

ពូជពង្សលោកអាដាម		**អ្នកដែលចូលរួមជាមួយព្រះគ្រីស្ត**
មានកំហុសដោយ-សារអំពើបាបរបស់លោកអាដាម	(១ កូរិនថូស ១៥:២២-២៣)	ព្រះជាម្ចាស់លើកលែងទោសតាមរយៈកិច្ចការរបស់ព្រះអម្ចាស់យេស៊ូនៅលើឈើឆ្កាង
និស្ស័យធ្លាក់ចុះទៅក្នុងអំពើបាប	(អេភេសូ ៤:២២-២៤), (២ កូរិនថូស ៥:១៧-១៨)	និស្ស័យថ្មី ដែលព្រះ-វិញ្ញាណប្រោសអោសបានវិសុទ្ធ
ការប្រព្រឹត្តអំពើបាប	(កាឡាទី ៥:១៩-២៤), (អេភេសូ ៥:៨-១០)	ការប្រព្រឹត្តអំពើល្អ
ស្ថាននរក	(មថ. ២៥:៤៦), (កាឡាទី ៦:៨)	ស្ថានបរមសុខ

សេចក្តីសង្គ្រោះ

ការសង្គ្រោះអស់កល្បរបស់យើង ជាអំណោយទានរបស់ព្រះជា-ម្ចាស់ ហើយយើងបានសង្គ្រោះតែដោយសារព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គប៉ុណ្ណោះ ។ នៅពេលដែលយើងកែប្រែចិត្តគំនិត យើងនឹងទទួលការសង្គ្រោះតាមរយៈជំនឿរបស់យើងលើព្រះគ្រីស្ត (រ៉ូម ៣:២១-២៦) ។ យើងមិនមែនបានសង្គ្រោះដោយសារយើងប្រព្រឹត្តអំពើល្អទេ តែដើម្បីប្រព្រឹត្តអំពើល្អវិញ (អេភេសូ ២:៨-១០) ។

មនុស្សបាបបានសង្គ្រោះ នៅពេលដែលគេបានកើតជាថ្មី (យ៉ូហាន ៣:៥) គឺដោយសារព្រះវិញ្ញាណដ៏វិសុទ្ធប្រទានជីវិតថ្មីដល់គេ ។ គ្រីស្តជនថ្មីចង់ប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយសារមានសេចក្តីស្រឡាញ់ (យ៉ូហាន ៣:៥-៨, ១៤:១៥, ២ កូរិនថូស ៥:១៧) ។

ហេតុអ្វីបានជាយើងមិនអាចជួយសង្គ្រោះខ្លួនឯង ដោយប្រព្រឹត្តអំពើល្អ ? ។

ពិធីកាច់នំបុ័ង

នៅពេលធ្វើពិធីកាច់នំបុ័ង ព្រះយេស៊ូគ្រីស្តបានបង្គាប់អោយយើងរំលឹកពីការសុគតរបស់ព្រះអង្គដើម្បីយើង (លូកា ២២:១៩) ។ ពិធីកាច់នំបុ័ង ជានិមិត្តរូបតំណាងសម្ពន្ធមេត្រីថ្មី គឺសម្ពន្ធមេត្រីដែលនាំអោយយើងទទួលបានការលើកលែងទោសពីព្រះជាម្ចាស់ដោយសារព្រះលោហិតរបស់ព្រះគ្រីស្ត (ម៉ាថាយ ២៦:២៦-២៨) ។ នំបុ័ង និង ទឹកទំពាំងបាយជូរតំណាងការ ដែលយើងបានចូលរួមជាមួយព្រះកាយ និង ព្រះលោហិតរបស់ព្រះគ្រីស្ត (១ កូរិនថូស ១០:១៦) ។ ពិធីកាច់នំបុ័ងក៏រំលឹកយើងអោយចាំថាព្រះគ្រីស្តនឹងយាងមកវិញដែរ (១ កូរិនថូស ១១:២៦) ។

ពិធីកាច់នំបុ័ងសំរាប់តែអ្នកជឿ ដែលបានទទួលពិធីជ្រមុជទឹកហើយប៉ុណ្ណោះ (កិច្ចការ ២:៣៨-៤២) ។ មុននឹងចូលរួមធ្វើពិធីកាច់នំបុ័ង យើងពិនិត្យមើលចិត្តយើងសិន និង លន់តួសារភាពអំពើបាបថ្វាយទៅព្រះជាម្ចាស់ដែរ (១ កូរិនថូស ១១:២៧-៣២) ។

© Project WorldReach © SEAN

ពិធីជ្រមុជទឹក

ការទទួលពិធីជ្រមុជទឹកបង្ហាញអំពីជំនឿ និង ការកែប្រែចិត្តគំនិតរបស់ពួកអ្នកជឿថ្មី ។ នេះជាជំហានទីមួយ ដែលអ្នកជឿថ្មីដែលបានកែប្រែចិត្តគំនិត ត្រូវតែធ្វើ (កិច្ចការ ២:៣៨-៤២, ៨:១២-១៣, ៨:៣៦-៣៨, ៩:១៧-១៩, ១០:៤៤-៤៨, ១៦:១៤-១៥, ១៦:៣០-៣៤, ១៨:៨) ។

ពិធីជ្រមុជទឹកមិនអាចធ្វើអោយយើងបានសង្គ្រោះទេ ។ ពិធីជ្រមុជទឹកគ្រាន់តែបង្ហាញពីការ ដែលព្រះជាម្ចាស់បានសង្គ្រោះយើងតាមរយៈជំនឿ ការកែប្រែចិត្តគំនិត និង ការជំរះសំអាតពីអំពើបាបដោយសារការសុគត និង ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះ-យេស៊ូ (កិច្ចការ ២២:១៦, ១ ពេត្រុស ៣:២១) ។

ពួកអ្នកចាស់ទុំរបស់ក្រុមជំនុំធ្វើពិធីជ្រមុជទឹក ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ (ម៉ាថាយ ២៨:១៩) ។

ពិធីជ្រមុជទឹកជានិមិត្តរូបតំណាងការស្លាប់ខាងអំពើបាបរបស់យើង រួមជាមួយព្រះគ្រីស្ត និង ការរស់ឡើងវិញជាមួយព្រះអង្គក្នុងជីវិតថ្មី (រ៉ូម ៦:៣-៨) ។

ព្រះគ្រីស្តបានជួយឱ្យយើងអាចទទួលការលើកលែងទោសអស់កល្ប ដោយសារការសុគតរបស់ព្រះអង្គ ហើយដោយសារព្រះអង្គមានព្រះជន្មរស់ឡើងវិញ ទើបព្រះអង្គធ្វើអោយយើងអាចចូលរួមក្នុងជីវិតអស់កល្បរបស់ព្រះអង្គ (យ៉ូហាន ១០:២៨, រ៉ូម ៦:២៣) ។ ទូកបានសង្គ្រោះលោកណូអេ និង គ្រួសាររបស់គាត់យ៉ាងណា ព្រះយេស៊ូក៏នឹងជួយយើងអោយរួចពីសេចក្តីស្លាប់ទៅរកសិរីរុងរឿងរបស់ព្រះអង្គយ៉ាងនោះដែរ (យ៉ូហាន ១៤:១-៣, កូឡូស ៣:៤) ។



ជំនឿ

ការកែប្រែចិត្តគំនិត និង ជំនឿ រួមគ្នាជាមធ្យោបាយសំរាប់អោយយើងបានសង្គ្រោះ ។ ព្រះវិញ្ញាណដ៏វិសុទ្ធនាំឱ្យយើងជឿ ហើយជំនឿ គឺជាការទុកចិត្តទាំងស្រុង ដោយគ្មានលក្ខខ័ណ្ឌ ។ មនុស្សបាបទទួលស្គាល់ថាខ្លួនបានធ្វើបាប ហើយវិលមករកព្រះជាម្ចាស់វិញ ដោយកែប្រែចិត្តគំនិត ហើយទទួលព្រះគ្រីស្តជាព្រះសង្គ្រោះ និង ព្រះអម្ចាស់របស់ខ្លួន ។

ជំនឿពិត មិនមែនគ្រាន់តែជាការ « ជឿលើ » ដំណឹងល្អប៉ុណ្ណោះទេ គឺព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ដែលនៅក្នុងយើងធ្វើអោយយើងដឹងជាក់ថា ព្រះជាម្ចាស់បានលើកលែងទោសអោយយើងហើយ ។ ព្រះជាម្ចាស់ធ្វើអោយយើងកើតជាថ្មីក្នុងព្រះគ្រីស្ត តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ (ទីតុស ៣:៥-៦) ។

ជំនឿដែលគ្មានការប្រព្រឹត្តល្អ ជាជំនឿស្លាប់ហើយ (យ៉ាកុប ២:២៦) ។ ជំនឿបែបនេះ គ្មានលទ្ធផលអ្វីទាំងអស់ ឯចំណែកជំនឿរស់ នាំអោយមនុស្សប្រតិបត្តិតាមព្រះគ្រីស្ត និង អរព្រះគុណព្រះគ្រីស្តអស់ពីដួងចិត្ត ដោយសារទទួលស្គាល់ថា ព្រះអង្គបានរងទុក្ខឈឺចាប់លើឈើឆ្កាង ដើម្បីជួយសង្គ្រោះយើងអោយរួចពីបាប ។

- អ្នកដឹកនាំសកម្ម គឺជា « អ្នកចាស់ទុំ » (គ្រូគង្វាល) និង « អ្នកជំនួយ » ដែលចេះជួយមនុស្សដោយធ្វើការងារបំរើ (១ ធីម៉ូថេ ៣:១-១៣, ១ ពេត្រុស ៥:១-៤, កិច្ចការ ៦:១-៧, ១៤:២៣) ។

អាគារមិនមែនជាក្រុមជំនុំទេ ។



ក្រុមជំនុំរបស់ព្រះគ្រីស្ត
គឺជាមនុស្ស ។

រួមគ្នាក្នុងព្រះគ្រីស្ត ។

© Project WorldReach © SEAN

ក្រុមជំនុំដំបូងៗរបស់ពួកសាវក ជាគំរូសំរាប់យើង ។ ក្រុមជំនុំទាំងនោះមានលក្ខណៈពិសេសដូចខាងក្រោមនេះ :

- ពួកគេទទួលស្គាល់ថា ព្រះគ្រីស្តជាសិរសាតែមួយគត់របស់ពួកគេ (កូឡូស ១:១៨) ។
- ព្រះគម្ពីរជាខ្នាតគំរូតែមួយគត់សំរាប់គោលជំនឿ និង កិច្ចការបំរើទាំងអស់របស់ពួកគេ (កិច្ចការ ២:៤២, ២ ធីម៉ូថេ ៣:១៦-១៧) ។
- សមាជិកម្នាក់ៗទទួលពិធីជ្រមុជទឹក និង ធ្វើពិធីកាច់នំប៉័ងជាមួយគ្នា (កិច្ចការ ២:៣៧-៤៣) ។
- សមាជិកម្នាក់ៗមានកិច្ចការបំរើ ស្របទៅតាមអំណោយទានរបស់ខ្លួន (រ៉ូម ១២:៤-៨, ១ កូរិនថូស ជំពូក ១២) ។ ពាក្យ « សមាជិក » បកប្រែពីពាក្យដើមនៅក្នុងព្រះគម្ពីរជាភាសាក្រិក ដែលមានន័យថា សរីរាង្គ ឬ អវយវៈ ឬ ផ្នែកផ្សេងៗនៃរូបកាយ (រ៉ូម ១២:៤-៥) ។ បើសិនជាអ្នកជឿម្នាក់ដែលជា « ជើង » មិនព្រមបំរើព្រះជាម្ចាស់ ព្រះកាយនឹងពិការ មិនអាចមានដំណើរការត្រឹមត្រូវ ពីព្រោះតែមានមនុស្សម្នាក់នោះមិនបានប្រតិបត្តិតាមព្រះអម្ចាស់ ។

យើងរស់ឡើងវិញរួមជាមួយព្រះគ្រីស្ត និង ចាប់ផ្តើមជីវិតថ្មីដោយសារជំនឿ (២ កូរិនថូស ៥:១៧, កាឡាទី ២:២០) ។

យោងទៅតាម អេភេសូ ២:៨-១០ ការសង្គ្រោះ :

☐ ជារង្វាន់សំរាប់អោយមនុស្ស ដែលប្រព្រឹត្តល្អ ។

☐ នាំអោយប្រព្រឹត្តល្អ ។



ព្រះហឫទ័យប្រណីសន្តោសដ៏បរិបូណ៌

យើងបានសង្គ្រោះ ដោយសារព្រះហឫទ័យប្រណីសន្តោស និង ព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ប៉ុណ្ណោះ ។ សេចក្តីស្រឡាញ់របស់ព្រះអង្គចំពោះយើងគ្មានព្រំដែនទេ ។ ព្រះជាម្ចាស់បានបង្ហាញសេចក្តីស្រឡាញ់នេះ តាមរយៈការសុគតរបស់ព្រះ-គ្រីស្ត ដែលជាព្រះសង្គ្រោះរបស់យើង (រ៉ូម ៥:៨, អេភេសូ ១:៧- ៨, ២:៤-៧) ។

ពលិកម្មដ៏អស់កល្បរបស់ព្រះគ្រីស្ត គឺសំរាប់អោយអ្នកជឿបានទទួលសេចក្តីសង្គ្រោះ (រ៉ូម ៣:២១-២៦, ៥:១-២, ហេប្រឺ ៩:១២) ។

គ្មានមនុស្សណាម្នាក់សមនឹងទទួលព្រះហឫទ័យប្រណីសន្តោសនេះទេ ព្រោះយើងគ្រប់គ្នាសុទ្ធតែបានធ្វើបាបទាស់នឹងព្រះជាម្ចាស់ដ៏បរិសុទ្ធ ។ ប៉ុន្តែ ដោយសារព្រះជាម្ចាស់ស្រឡាញ់យើងខ្លាំងណាស់ ទើបព្រះអង្គជ្រើសរើសយើងអោយបានសង្គ្រោះ តាំងពីមុនកំណើតពិភពលោកមកម្ល៉េះ (អេភេសូ ១:៤-៦) ។

ព្រះជាម្ចាស់ ទោះជាជួបបញ្ហា ឬ ការលំបាកក៏ដោយ (យ៉ូហាន ១៤:១៥, ១៧:១៧, ២ កូរិនថូស ៣:១៨, ១ ពេត្រុស ១:៦-៩) ។

ការបានប្រកបដោយសិរីរុងរឿង :

នៅពេលដែលព្រះយេស៊ូយាងមកវិញ ព្រះជាម្ចាស់នឹងបំផ្លាស់បំប្រែយើង ហើយយើងនឹងឃើញព្រះជាម្ចាស់ច្បាស់មុខទល់នឹងមុខ (១ កូរិនថូស ១៣:១២, ១៥:៥១-៥៤) ។ ប៉ុន្តែ ចំពោះពួកអ្នកមិនជឿវិញ នឹង « ស្លាប់ជាលើកទីពីរ » (វិវរណៈ ២០:១១-១៥) ។

ព្រះកាយរបស់ព្រះគ្រីស្ត

ក្រុមជំនុំ/ព្រះសហគមន៍

ក្រុមជំនុំជាព្រះកាយរបស់ព្រះគ្រីស្ត គឺអស់អ្នកដែលបានទទួលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ តាមរយៈការកែប្រែចិត្តគំនិត និងជំនឿ ។ ក្រុមជំនុំមូលដ្ឋានជាក្រុមអ្នកជឿ ដែលប្តេជ្ញាចិត្តប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះជាម្ចាស់ ។

© Project WorldReach © SEAN

ការបង្ហាញអោយដឹងជាក់ថាមានបាប :

ព្រះវិញ្ញាណដ៏វិសុទ្ធធ្វើអោយយើងដឹងថា យើងមានបាបតាមរយៈព្រះគម្ពីរ និង មនសិការរបស់យើង (យ៉ូហាន ១៦:៨-១១, រ៉ូម ១០:១៧) ។

ការកើតជាថ្មី :

នៅពេលដែលយើងជឿលើព្រះគ្រីស្ត ព្រះជាម្ចាស់ធ្វើឱ្យយើងបានកើតជាថ្មីខាងព្រលឹងវិញ្ញាណ និង ទទួលយើងជាបុត្រធីតារបស់ព្រះអង្គ ដោយប្រទានអោយយើងមានព្រះវិញ្ញាណរបស់ព្រះបុត្រាព្រះអង្គ គឺព្រះយេស៊ូគ្រីស្ត គង់ជាមួយ ។ តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ យើងបានរួមជាមួយព្រះកាយនៃព្រះគ្រីស្ត (យ៉ូហាន ១:១២, ១ កូរិនថូស ១២:១២-១៣, ១ ពេត្រុស ១:៣-៥) ។

ការប្រោសអោយបានវិសុទ្ធ :

ព្រះវិញ្ញាណដ៏វិសុទ្ធបំផ្លាស់បំប្រែយើង អោយបានដូចព្រះគ្រីស្ត ហើយជួយយើងអោយអាចរស់នៅសក្តិសមនឹងព្រះអង្គ និង ជំរុញចិត្តយើងអោយធ្វើអំពើល្អ ។ យើងថ្វាយខ្លួនទៅព្រះជាម្ចាស់ទទួលពិធីជ្រមុជទឹក អធិស្ឋាន សិក្សា និង ប្រតិបត្តិតាមព្រះបន្ទូល

ហេតុអ្វីបានជាគ្មានមនុស្សណាម្នាក់អាចអួតខ្លួននៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់បាន ? (អេភេសូ ២:៨-១០) ។

_____

_____

_____

ភាពបរិសុទ្ធ និង ការគោរពប្រតិបត្តិតាមព្រះជាម្ចាស់

ការប្រោសឱ្យបានវិសុទ្ធមានពីរផ្នែក : មួយផ្នែកកើតមានភ្លាមៗ មួយផ្នែកទៀតកើតឡើងបន្តិចម្តងៗ ។

ពេលដែលយើងថ្វាយខ្លួនដាច់ដល់ព្រះជាម្ចាស់ ព្រះអង្គញែកយើងចេញពីលោកីយ៍ភ្លាម ដោយសារព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ ហើយព្រះអង្គធ្វើឱ្យយើងក្លាយជាបុត្រធីតារបស់ព្រះអង្គ គឺថា ជាប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះអង្គ ។ នៅចំពោះព្រះនេត្ររបស់ព្រះជាម្ចាស់ យើងបានវិសុទ្ធទាំងស្រុងហើយ (ហេប្រឺ ១០:១០) ។

ម៉្យាងទៀត ការប្រោសអោយបានវិសុទ្ធ ជាដំណើរការរីកចំរើនខាងព្រលឹងវិញ្ញាណ គឺថាអ្នកជឿបែរចេញពីអំពើបាប ដើម្បីប្រតិបត្តិតាមព្រះជាម្ចាស់ និង រស់នៅដើម្បីព្រះគ្រីស្តកាន់តែខ្លាំងឡើងៗ ។ ព្រះវិញ្ញាណដ៏វិសុទ្ធ នៅតែប្រោសយើងអោយបានគ្រប់លក្ខណ៍បន្តិចម្តងៗជារៀងរាល់ថ្ងៃ ។

ព្រះជាម្ចាស់ប្រោសយើងអោយបានវិសុទ្ធ គឺវិសុទ្ធគ្រប់ផ្នែកនៃជីវិតរបស់យើង ទាំងចរិតលក្ខណៈ ទាំងការប្រព្រឹត្តរបស់យើង ។ បានន័យថាយើង«លែង»រស់នៅតាមរបៀបចាស់ ហើយ«ប្រកាន់យក»របៀបរស់នៅថ្មី ដែលកាន់តែរីកចំរើនឡើងៗ រហូតទាល់តែយើងមានលក្ខណៈដូចព្រះគ្រីស្ត ។ នៅពេលដែលយើងស្លាប់ ឬក៏នៅពេលដែលព្រះគ្រីស្តយាងត្រឡប់មកវិញ យើងនឹងបានវិសុទ្ធគ្រប់លក្ខណៈ ព្រោះយើងនឹងបានឃើញភាពពិតរបស់ព្រះអង្គយ៉ាងច្បាស់ (១ យ៉ូហាន ៣:២-៣) ។

សេចក្តីសង្ខេបអំពីផែនការរបស់ព្រះជាម្ចាស់

ការជ្រើសរើសរបស់ព្រះជាម្ចាស់ :

ព្រះជាម្ចាស់បានជ្រើសរើសយើងក្នុងអង្គព្រះគ្រីស្ត តាំងពីមុនកំណើតពិភពលោកមកម្ល៉េះ (អេភេសូ ១:៤) ។

ការធ្លាក់ចុះក្នុងអំពើបាប :

លោកអាដាម និង មនុស្សទាំងអស់បានធ្វើបាប ហើយត្រូវទទួលទោស (រ៉ូម ៥:១២-២១) ។

ការប្រោសលោះ :

ព្រះអម្ចាស់យេស៊ូគ្រីស្តបានសុគត និង មានព្រះជន្មរស់ឡើងវិញដើម្បីយើង គឺព្រះអង្គចេញថ្លៃទោសនៃអំពើបាបរបស់យើង និងរំដោះយើងអោយមានសេរីភាព ពីការគ្រប់គ្រងរបស់មារសាតាំង និង ពីបំណងលោភលន់ខាងលោកីយ៍ ។ ឥឡូវនេះ យើងជាបុត្រធីតារបស់ព្រះយេស៊ូហើយ (២ កូរិនថូស ៥:១៤-២១, អេភេសូ ២:១-១០) ។

© Project WorldReach © SEAN

ជីវិតអស់កល្ប

ការសង្គ្រោះស្ថិតនៅអស់កល្ប (យ៉ូហាន ៣:១៦, ៥:២៤, ១ ពេត្រុស ១:៣-៩) ។ បើសិនជាអ្នកពិតជាបានសង្គ្រោះមែន (គឺថា មានជំនឿពិត និង កែប្រែចិត្តគំនិតពិត) ជីវិតអស់កល្ប ដែលព្រះយេស៊ូប្រទានដល់អ្នកនឹងគ្មានទីបញ្ចប់ទេ (យ៉ូហាន ១០:២៧-៣០) ។

ដើម្បីអោយបានជីវិតអស់កល្ប យើងមិនមែនអាចពឹងលើខ្លួនយើងបានទេ គឺត្រូវពឹងលើព្រះយេស៊ូគ្រីស្តវិញ ។

ព្រះជាម្ចាស់បានជ្រើសរើសយើងក្នុងអង្គព្រះគ្រីស្ត តាំងពីមុនកំណើតពិភពលោកមកម្ល៉េះ ដើម្បីអោយយើងបានសង្គ្រោះ (រ៉ូម ៩:១១, យ៉ូហាន ១៥:១៦, អេភេសូ ១:៤, កិច្ចការ ១៣:៤៨) ។ ហេតុនេះ គ្មានអ្វីអាចបំបែកយើងពីព្រះអង្គបានទេ ទោះបីមារសាតាំងក្តី សេចក្តីស្លាប់ក្តី ទុក្ខលំបាកក្តី ឬ អ្វីផ្សេងក៏ដោយ (យ៉ូហាន ៥:២៤, ១០:២៧-៣០, រ៉ូម ៨:៣៥-៣៩) ។

ព្រះវិញ្ញាណដ៏វិសុទ្ធបានដៅសញ្ញាសំគាល់យើង ជាប្រជារាស្ត្រពិតរបស់ព្រះជាម្ចាស់ (អេភេសូ ១:១៣-១៤) ។

ភាពបរិសុទ្ធជាផលផ្លែនៃព្រះវិញ្ញាណដ៏វិសុទ្ធ ដែលរួមមានគុណសម្បត្តិទាំងប៉ុន្មាន ដែលមានចែងនៅក្នុង កាឡាទី ៥:២២-២៣ និង អេភេសូ ៥:៩ :

- សេចក្តីស្រឡាញ់
- អំណរ
- សេចក្តីសុខសាន្ត
- ចិត្តអត់ធ្មត់
- ចិត្តសប្បុរស
- ចិត្តសន្តោសមេត្តា
- ជំនឿ (ស្មោះត្រង់)
- ចិត្តស្លូតបូត
- ចេះទប់ចិត្តខ្លួនឯង
- សេចក្តីសុចរិត
- សេចក្តីពិត

© Project WorldReach © SEAN

តើនៅក្នុងជីវិតអ្នក អ្នកខ្វះគុណសម្បត្តិណាខ្លះ ? ។

_____

_____

_____

_____

_____

_____

_____

_____

តើអ្នក**ផ្សាយដំណឹងល្អ**អំពីព្រះគ្រីស្តជាប់ជានិច្ចដែរឬទេ ? ។ ____

តើអ្នក**ថ្វាយដង្វាយ** ដោយចិត្តអំណរដែរឬទេ ? ។ _____

តើអ្នកស្រឡាញ់ព្រះជាម្ចាស់អស់ពីចិត្តគំនិត អស់ពីស្មារតី អស់ពីប្រាជ្ញា និង អស់ពីកំឡាំងកាយ ហើយ**ស្រឡាញ់មនុស្សឯទៀត**ឱ្យបានដូចស្រឡាញ់ខ្លួនឯងដែរឬទេ ? ។ _____



យើងត្រូវសម្លាប់អ្វីៗ ដែលជាបំណងលោភលន់ខាងលោកីយ៍ចោលអោយអស់ (រ៉ូម ៨:១៣, កូឡូស ៣:៥) ។

© Project WorldReach © SEAN